# ការត្រួតពិនិត្យផ្នែកការលូតលាស់

__តើការត្រួតពិនិត្យគឺជាអ្វី?__

ការត្រួតពិនិត្យផ្នែកការលូតលាស់ (developmental screening) គឺជាវិធីមួយក្នុងការពិនិត្យមើលថាកូនរបស់អ្នកកំពុងធំធាត់ ស្វែងយល់ និងលូតលាស់ក្នុងរបៀបណា។ អ្នកអាចពិភាក្សាជាមួយនឹងគ្រូពេទ្យរបស់កូនអ្នកអំពីការទទួលធ្វើការត្រួតពិនិត្យដោយមិនគិតថ្លៃ។ ជាញឹកញាប់ ពួកគេប្រើប្រាស់ឯកសារផ្សេងៗដូចជាឯកសារ Ages and Stages Questionnaire (ASQ) (បញ្ជីសំណួរស្ទង់មតិអំពីអាយុ និងដំណាក់កាលលូតលាស់) ហើយនិងឯកសារ Survey of Well-being of Young Children (SWYC) (ការស្ទង់មតិអំពីសុខុមាលភាពរបស់កុមារតូចៗ)។

ការត្រួតពិនិត្យនានាជួយគ្រូពេទ្យឱ្យបានដឹងថាកូនរបស់អ្នកកំពុងផ្លាស់ប្តូរ និងលូតលាស់ក្នុងរបៀបណា។ ពួកគេក៏អាចជួយស្វែងរកចំណុចបង្កការព្រួយបារម្ភណាមួយអំពីរបៀបដែលកូនរបស់អ្នកគិត ធ្វើចលនា និយាយ ឬប្រកាន់អាកប្បកិរិយាផងដែរ។

__ទីកន្លែងទទួលធ្វើការត្រួតពិនិត្យ__

អ្នកអាចទទួលធ្វើការត្រួតពិនិត្យដោយមិនគិតថ្លៃនៅតាមការិយាល័យរបស់គ្រូពេទ្យកូនអ្នក។

CAMBODIAN 10/2024

អ្នកមិនមែនមានតែម្នាក់ឯងនោះទេនៅក្នុងដំណើរការនេះ។ ដៃគូរបស់ក្រុមគ្រួសារនានាពីគម្រោង ENRICH-LAC គឺនៅទីនេះ ដើម្បីជួយ និងគាំទ្រដល់អ្នកក្នុងការបង្កើតអនាគតដ៏កាន់តែល្អមួយសម្រាប់កូនរបស់អ្នក។

**ទាក់ទងមកកាន់យើងខ្ញុំតាមរយៈ:**

__ENRICH@ph.lacounty.gov__



គម្រោង ENRICH-LAC គឺជាការសហការរវាង៖

Children's Hospital Los Angeles | County of Los Angeles | County of Los Angeles Public Health

ឯកសារធនធាននេះគឺបានគាំទ្រដោយរដ្ឋបាលធនធាន និងសេវាកម្មផ្នែកសុខភាព (HRSA) នៃក្រសួងសេវាកម្មផ្នែកសុខភាព និងមនុស្សជាតិ (HHS) របស់សហរដ្ឋអាមេរិក ដែលជាផ្នែកមួយនៃការផ្តល់ទឹកប្រាក់សរុបចំនួន $1,000,000 ដោយមិនមានទទួលជំនួយផ្នែកប្រាក់កាសអ្វីទាំងអស់ពីប្រភពមិនមែនរដ្ឋាភិបាល។ ខ្លឹមសារទាំងឡាយគឺជារបស់អ្នកនិពន្ធទាំងឡាយ ហើយមិនមែនចាំបាច់ជាតំណាងលក្ខណៈផ្លូវការ ឬក៏មិនមែនចាំបាច់ជាការយល់ព្រមទាំងស្រុងពី HRSA ឬ HHS ឬក៏រដ្ឋាភិបាលសហរដ្ឋអាមេរិកនោះទេ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ HRSA.gov។



*គម្រោងការឆ្លើយតបទៅនឹងតម្រូវការពេលនៅតូចៗ ដើម្បីឱ្យទារក និងកុមារមានសុខភាពល្អ របស់ខោនធី Los Angeles (Early Needs Response for Infant and Child Health - Los Angeles County)*

# ស្វែងយល់អំពីគម្រោង ENRICH-LAC

ENRICH LOS ANGELES COUNTY

# ដៃគូរបស់ក្រុមគ្រួសារនានា (Family Partners) ពីគម្រោង ENRICH-LAC គឺនៅទីនេះ ដើម្បីជួយ និងគាំទ្រដល់អ្នក ខណៈដែលអ្នកថែទាំសុខភាពរបស់កូនអ្នក។

## អំពីសេវាកម្មផ្សេងៗពីគម្រោង ENRICH-LAC

គម្រោង ENRICH-LAC គឺនៅទីនេះ ដើម្បីជួយដល់ក្រុមគ្រួសារ និងអ្នកផ្តល់ការថែទាំនានារបស់កុមារដែលមានតម្រូវការផ្សេងៗផ្នែកការលូតលាស់ ការអប់រំ និងការថែទាំសុខភាពជាលក្ខណៈពិសេស។ ដៃគូរបស់ក្រុមគ្រួសារនានាគឺនៅទីនេះ ដើម្បីនាំផ្លូវដល់អ្នកឆ្លងកាត់ដំណើរការនេះ។

## របៀបដែលដៃគូរបស់ក្រុមគ្រួសារនានាពីគម្រោង ENRICH-LAC អាចជួយបាន

### ស្គាល់អំពីតម្រូវការផ្សេងៗ

យើងខ្ញុំអាចជួយអ្នកក្នុងការស្វែងរក និងទទួលបានសេវាកម្មផ្សេងៗ ដើម្បីគាំទ្រដល់តម្រូវការនានាផ្នែកការលូតលាស់ និងការអប់រំរបស់កូនអ្នក។

### ការផ្តល់ជំនឿចិត្ត និងការគាំទ្រមតិ

យើងខ្ញុំអាចជួយអ្នកឱ្យមានទំនុកចិត្តកាន់តែច្រើន និងជួយអ្នកឱ្យស្វែងយល់អំពីរបៀបបញ្ចេញមតិចំពោះតម្រូវការនានារបស់កូន និងក្រុមគ្រួសាររបស់អ្នក ផងដែរ។



### ជំហានទី 1៖ ការត្រួតពិនិត្យផ្នែកការលូតលាស់

ចាប់ផ្តើមដំណើរនៃការលូតលាស់របស់កូនអ្នកដោយការត្រួតពិនិត្យនៅការិយាល័យរបស់គ្រូពេទ្យពួកគេ។ ការធ្វើបែបនេះនឹងជួយធ្វើឱ្យប្រាកដថាកូនរបស់អ្នកទទួលជំនួយដែលត្រឹមត្រូវបានឆាប់រហ័ស។

### ជំហានទី 2៖ ភ្ជាប់ទំនាក់ទំនងទៅកាន់សេវាកម្មផ្សេងៗ

ដៃគូរបស់ក្រុមគ្រួសារនានារបស់យើងខ្ញុំអាចជួយអ្នកក្នុងការស្វែងរកសេវាកម្មជំនួយដែលត្រឹមត្រូវសម្រាប់កូនរបស់អ្នកបាន។





### ជំហានទី 3៖ ចាត់តាំង និងសម្រេចគោលដៅផ្សេងៗ

យើងខ្ញុំនឹងសហការជាមួយនឹងអ្នក ដើម្បីចាត់តាំងគោលដៅផ្សេងៗសម្រាប់សុខភាពអាកប្បកិរិយា ការអប់រំ និងចំណុចផ្សេងទៀតរបស់កូនអ្នក។ ពួកយើងអាចតាមដានការឈានទៅមុខ និងអបអរចំពោះភាពជោគជ័យនានាបានជាមួយគ្នា។

## ធនធានផ្សេងៗផ្នែកការលូតលាស់នាពេលកុមារភាព

### ព្រឹត្តិការណ៍សំខាន់ៗចំពោះការលូតលាស់

ជំនាញនានាដូចជាការក្រោកអង្គុយ និងការដើរជំហានទីមួយគឺហៅថាព្រឹត្តិការណ៍សំខាន់ៗចំពោះការលូតលាស់ (developmental milestones)។ ចូរស្កេនកូដ QR នេះ ដើម្បីស្វែងយល់បន្ថែមអំពីព្រឹត្តិការណ៍សំខាន់ៗចំពោះការលូតលាស់។

ស្កេនកូដនេះ:

### កម្មវិធី EARLY START ផ្សេងៗ

ចូរស្កេនកូដ QR នេះ ដើម្បីស្វែងយល់បន្ថែមអំពីកម្មវិធី Early Start (កម្មវិធីផ្តល់ជំនួយផ្នែកការទប់ស្កាត់មិនឱ្យមានបញ្ហាទាក់ទងទៅនឹងការលូតលាស់) ផ្សេងៗសម្រាប់ទារក និងកុមារតូចៗ។

ស្កេនកូដនេះ:

### កម្មវិធី EARLY LEARNERS របស់បណ្ណាល័យនៅក្នុងខោនធី LA

ចូរស្កេនកូដ QR នេះ ដើម្បីទទួលបានធនធានផ្សេងៗក្នុងការជួយឆ្លើយនឹងសំណួរនានា ស្វែងរកដំបូន្មាននិងដំណោះស្រាយ ហើយនិងត្រៀមខ្លួនដោយសកម្មទាក់ទងទៅនឹងសុខភាពផ្លូវកាយនិងផ្នែកអាកប្បកិរិយា ទំនាក់ទំនងក្នុងសង្គម ការរៀនសូត្រ និងសុខុមាលភាពរបស់កូនអ្នក។

ស្កេនកូដនេះ:

(កម្មវិធី Early Learners គឺជាកម្មវិធីនៅតាមបណ្ណាល័យសម្រាប់កុមារតូចៗដែលចង់ចាប់ផ្តើមរៀនសូត្រ។)